ធនាគារជាតិនៃកម្ពុជា

អង្គការសហប្រជាជាតិ
ប្រទេសកម្ពុជា

*ថ្ងៃពុធ ៤ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤*

# សេចក្តីថ្លែងការណ៍រួម
# រវាង ធនាគារជាតិនៃកម្ពុជា និង អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា
# ស្តីពី
# ដំណើរការពិគ្រោះយោបល់ជាមួយពហុភាគីពាក់ព័ន្ធ ស្តីពី មីក្រូហិរញ្ញវត្ថុនៅកម្ពុជា

កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា និងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានសហការរៀបចំសម្របសម្រួលការពិគ្រោះយោបល់ជាមួយពហុភាគីពាក់ព័ន្ធ ស្តីពី មីក្រូហិរញ្ញវត្ថុនៅកម្ពុជា បន្ទាប់ពីមានការកើនឡើងនៃការព្រួយបារម្ភចំពោះកំណើនយ៉ាងឆាប់រហ័សនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងការប្រទាក់ក្រឡាគ្នាជាមួយបញ្ហាប្រឈមផ្សេងទៀត ដូចជាការជាប់បំណុល ជាដើម។ ដំណើរការពិគ្រោះយោបល់នេះ មានគោលបំណងសម្របសម្រួលឱ្យមានការចូលរួមពិភាក្សាក្នុងន័យស្ថាបនាពីភាគីពាក់ព័ន្ធ បង្កើតឱ្យមានការយល់ដឹងរួមគ្នាអំពីបញ្ហាប្រឈមនានា និងកំណត់សកម្មភាពនិងការប្តេជ្ញាចិត្តជាក់លាក់ ដែលអាចគាំទ្រដល់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការដោះស្រាយបញ្ហាប្រឈម និងចាប់យកកាលានុវត្តភាពក្នុងការពង្រឹងវិស័យធនាគារនិងហិរញ្ញវត្ថុ។ កិច្ចសន្ទនាតាមក្រុមនីមួយៗ និងកិច្ចប្រជុំបច្ចេកទេសជាមួយពហុភាគីពាក់ព័ន្ធ ត្រូវបានរៀបចំឡើងជាបន្តបន្ទាប់ ហើយមានការចូលរួមពិគ្រោះយោបល់ពីតំណាងក្រុមនិងស្ថាប័នចំនួន ១០០ ផ្សេងគ្នា រួមមាន៖ តំណាងមកពីរាជរដ្ឋាភិបាល និយ័តករ ស្ថាប័ននិងសមាគមវិជ្ជាជីវៈធនាគារនិងហិរញ្ញវត្ថុ វិនិយោគិន សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ។

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤ កិច្ចសន្ទនាកម្រិតខ្ពស់រវាងពហុភាគីពាក់ព័ន្ធដ៏មានសារៈសំខាន់មួយ ត្រូវបានរៀបចំឡើង ដើម្បីពិចារណាលើលទ្ធផលដែលទទួលបានពីដំណើរការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងដាក់ចេញនូវផែនការសម្រាប់ជំហានបន្ទាប់។ ភាគីពាក់ព័ន្ធបានអនុម័តសកម្មភាពមួយចំនួនដែលនឹងត្រូវអនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង ដោយបែងចែកជាផ្នែកអាទិភាពចំនួន ៥ ដូចខាងក្រោម៖

១. **បទប្បញ្ញត្តិនិងការត្រួតពិនិត្យ៖** តម្រូវឱ្យអនុវត្តតាមក្រមប្រតិបត្តិ និងគោលការណ៍ផ្តល់ឥណទាន ពង្រឹងកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងនិយ័តករ និងធានាប្រសិទ្ធភាពនៃយន្តការស្វ័យនិយ័តកម្ម។

២. **ការគាំទ្រដល់អតិថិជនឥណទាន៖** ពង្រឹងយន្តការដោះស្រាយបណ្តឹង បង្កើតក្រុមការងាររៀបចំយន្តការឯកភាពក្នុងការពិគ្រោះយោបល់និងសម្រុះសម្រួលបំណុល និងលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុដល់អតិថិជន។

៣. **ការពង្រឹងផ្នែកបច្ចេកទេស៖** ប្រមូល/ចែករំលែកទិន្នន័យគួបសរុប ដាក់ចេញលិខិតបទដ្ឋានគតិយុត្តស្តីពីឥណទានរៀបចំឡើងវិញនិង/ឬបុនហិរញ្ញប្បទាន និងកំណត់និយមន័យមីក្រូឥណទានឱ្យមានលក្ខណៈស្តង់ដា។

៤. **ការសម្រួចវិធានការលើការផ្តល់កម្ចីក្រៅផ្លូវការ និងតួនាទីអាជ្ញាធរមូលដ្ឋាន៖** ពង្រឹងការអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់កម្ចីក្រៅផ្លូវការ និងពង្រឹងការអនុវត្តតួនាទីរបស់អាជ្ញាធរមូលដ្ឋាន។

៥. **សេវាធានារ៉ាប់រង៖** សាកល្បងគម្រោងធានារ៉ាប់រងសម្រាប់ហានិភ័យកសិកម្ម ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ក្រោមក្របខ័ណ្ឌនៃសហគមន៍កសិកម្មទំនើប និងរៀបចំក្រុមការងារគាំទ្រដល់ការបង្កើតសហគមន៍កសិកម្មទំនើបសម្រាប់សហគមន៍ជនជាតិដើមភាគតិច។

តំណាងដែលបានចូលរួមក្នុងកិច្ចសន្ទនាកម្រិតខ្ពស់រវាងពហុភាគីពាក់ព័ន្ធ បានបញ្ជាក់ពីការប្តេជ្ញាចិត្តក្នុងការជំរុញភាពត្រឹមត្រូវ និងតម្លាភាពក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ដែលបំពេញសេចក្តីត្រូវការរបស់ប្រជាជនកម្ពុជា តាមរយៈការលើកកម្ពស់ការផ្តល់និងការប្រើប្រាស់សេវាធនាគារនិងហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងបរិយាបន្ន។

ដំណើរការពិគ្រោះយោបល់នេះនឹងនៅតែបន្ត ដោយកិច្ចប្រជុំបន្ទាប់ជាមួយភាគីពាក់ព័ន្ធគ្រោងនឹងរៀបចំឡើងក្នុងខែមករា ឆ្នាំ២០២៥ ដើម្បីវាយតម្លៃ និងតាមដានវឌ្ឍនភាពនៃសកម្មភាពដែលអនុវត្តដោយភាគីពាក់ព័ន្ធ។

ភាគីពាក់ព័ន្ធបន្តប្តេជ្ញាចិត្តក្នុងការធានាថា ប្រព័ន្ធអេកូឡូស៊ីធនាគារនិងហិរញ្ញវត្ថុ នឹងជួយពង្រឹងសិទ្ធិអំណាចរបស់ប្រជាជនជាពិសេសក្រុមងាយរងគ្រោះ គាំទ្ររបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរួមចំណែកដល់ស្ថិរភាពសេដ្ឋកិច្ចជារួមរបស់កម្ពុជា។

បញ្ជីលម្អិតនៃសកម្មភាពជាអាទិភាពមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ។


**ទំនាក់ទំនង ៖**

១. អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៨៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_OGSSLjXZXvbcATfA

២. កញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនង និងស្វែងរកការគាំទ្រ
នៃ**ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា**
ទូរស័ព្ទ ៖ (៨៥៥) ១១ ៨៨ ៥៧ ៦៦
អ៊ីម៉ែល ៖ sreysros.keo@un.org